## នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/២៣-០៩-២០២១-អ.វ.ត.ក/អ.ជ.ត.ក(០៦)

ភាគីដាក់ឯកសារ: មេធាវីការពារក្តីរបស់ យឹម ទិត្យ

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០២១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Nov-2021, 14:12
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចដែលបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិ អ.វ.ត.ក

---

**ដាក់ដោយ៖**

**សហមេធាវី**

ស៊ូ មូស្សេន្នី
Suzana TOMANOVIĆ

**ផ្ញើជូន៖**

**អង្គជំនុំជម្រះតុលាការកំពូល**

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម C. N. JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

ជា លាង

Brenda J HOLLIS

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ក្នុងសំណុំរឿង 004**

# សេចក្តីផ្តើម

1. លោក យឹម ទិត្យ តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តទៅនេះសូមដាក់ជូនទៅអង្គជំនុំជម្រះតុលាការកំពូល(“អ.ជ.ត.ក”)នូវចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចដែលបានតម្រូវដោយក្របខ័ណ្ឌគតិយុត្ត អ.វ.ត.ក (“បណ្តឹងសាទុក្ខរបស់ ស.ព.អ”) ជាភាសាអង់គ្លេស និងភាសាខ្មែរ (“ចម្លើយតប”)។ មេធាវីការពារក្តីស្នើសុំដោយគោរពចំពោះ អ.ជ.ត.ក មេត្តាធ្វើការបដិសេធមិនអនុវត្តយុត្តាធិការដែលមានជាប់មកជាមួយរបស់ខ្លួនលើសំណុំរឿង០០៤ ដោយសារតែនៅពេលនេះ ស.ច.ស មានយុត្តាធិការផ្តាច់មុខទៅលើសំណុំរឿងនេះ។ អ.ជ.ត.ក គួរតែបដិសេធបណ្តឹងសាទុក្ខរបស់ ស.ព.អ តាំងពីដំបូង (*in limine*)។ ម្យ៉ាងវិញទៀត អ.ជ.ត.ក គួរតែបដិសេធបណ្តឹងសាទុក្ខរបស់ ស.ព.អ ដោយសារមូលដ្ឋាន ក, ខ និង គ ស្វែងរកការដោះស្រាយឡើងវិញដោយមិនត្រូវបានអនុញ្ញាតនូវបញ្ហា ដែលបានសម្រេចពីមុន ហើយមូលដ្ឋាន ឃ គឺមិនពាក់ពន្ធ័ដោយហេតុថាការសម្រេចតាមផ្លូវតុលាការគឺជាការអនុវត្តមិនចាំបាច់។ លើសពីនេះទៀត មូលដ្ឋានរបស់ ស.ព.អ ទាំងអស់ គឺមិនអាចទទួលយកបាននៅចំពោះមុខ អ.ជ.ត.ក ឡើយ ដោយអនុលោមតាមវិធាន ១០៤(១) និង ១០៥(៤)។

## I. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះ បានចេញ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ*នៅក្នុងសំណុំរឿង ០០៤ (សេចក្តីពិចារណារបស់ អ.ប.ជ)[1]។

3. នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ”) បានដាក់សំណើសុំទៅ អ.ជ.ត.ក តាមរយៈសារអេឡិចត្រូនិច ស្នើសុំពន្យាររយៈពេលកំណត់ដាក់សេចក្តីសន្និដ្ឋានជូន អ.ជ.ត.ក ពាក់ព័ន្ធនឹងករណីដែល ស.ព.អ បានអះអាងថា “ជាធម្មតា សេចក្តីសន្និដ្ឋាននេះរំពឹងថានឹងត្រូវដាក់ [...] ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីពិចារណាលើសំណុំរឿង ០០៤”[2]។

---

[1] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារលេខ D381/45 និង D382/43។

[2] សារអេឡិចត្រូនិចពីសហព្រះរាជអាជ្ញាអន្តរជាតិ “សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលដាក់សារណាក្នុងសំណុំរឿង០០៤” ចុះថ្ងៃ២៣ ខែកញ្ញា ឆ្នាំ២០២១។

4. នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ មេធាវីការពារក្ដីបានឆ្លើយតបតាមរយៈសារអេឡិចត្រូនិច ដោយជំទាស់ការអះអាងរបស់ ស.ព.អ ថា សេចក្ដីពិចារណារបស់ អ.ប.ជ គឺជាសេចក្ដីសម្រេចបើកផ្លូវប្ដឹងសាទុក្ខទៅ អ.ជ.ត.ក ហើយវាមានភាពចាំបាច់ត្រូវស្ដាប់សេចក្ដីសន្និដ្ឋានជាមុនពីមេធាវីការពារក្ដីមុនពេលសម្រេចលើបញ្ហានេះ[3]។

5. នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ អ.ជ.ត.ក បានចេញ*សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលដាក់សេចក្ដីសន្និដ្ឋានរបស់ខ្លួន ពាក់ព័ន្ធនឹងសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះលើដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤*[4]។

6. នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ មេធាវីការពារក្ដីបានដាក់ *សំណើរបស់ យឹម ទិត្យ សុំសហចៅក្រមស៊ើបអង្កេតឱ្យ បញ្ជប់ បោះត្រា ដាក់បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារជាបន្ទាន់* (សំណើរបស់មេធាវីការពារក្ដីស្នើទៅ ស.ច.ស") ជាភាសាអង់គ្លេស ហើយត្រូវបានជូនដំណឹងនៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០២១[5]។ សំណៅជាភាសាខ្មែរត្រូវបានជូនដំណឹងនៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០២១។

7. ទោះយ៉ាងណាក្ដី ដោយមិនយកចិត្តទុកដាក់ចំពោះអត្ថិភាពនៃស្ថាប័នតុលាការដែលដំណើរការពេញលេញ នៅក្នុង អ.វ.ត.ក ដូចជា ការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស), អង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះសាលាដំបូង (អ.ជ.ដ) ស.ព.អ បានដាក់បណ្ដឹងសាទុក្ខរបស់ខ្លួនទៅ អ.ជ.ត.ក នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ហើយត្រូវបានជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរ នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០២១។[6]

---

[3] សារអេឡិចត្រូនិចពីមេធាវីការពារក្ដី "កម្មវត្ថុ៖ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលដាក់សារណាក្នុងសំណុំរឿង០០៤" ចុះថ្ងៃ២៣ ខែកញ្ញា ឆ្នាំ២០២១។

[4] *សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលដាក់សារណារបស់គាត់ពាក់ព័ន្ធនឹងសេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤* ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ ឯកសារលេខ No. 2/2។

[5] *សំណើរបស់ យឹម ទិត្យ សុំសហចៅក្រមស៊ើបអង្កេតឱ្យ បញ្ចប់ បោះត្រា ដាក់បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារជាបន្ទាន់* ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ឯកសារលេខ D386។

[6] *បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចដែលបានតម្រូវ ដោយក្របខ័ណ្ឌគតិយុត្តិ អ.វ.ត.ក* ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ឯកសារលេខ No. 2។

## II. ច្បាប់ជាធរមាន

8. វិធាន ២១ នៃវិធានផ្ទៃក្នុងចែងត្រង់ផ្នែកពាក់ព័ន្ធថា៖

១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ផលប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។

ក្នុងបរិបទនេះ៖

ក-ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ នីតិវិធីត្រូវធានាឲ្យបាននូវភាពដាច់ដោយឡែកពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និងអាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស។

ខ-បុគ្គលទាំងឡាយដែលរកឃើញថា ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា និងត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត។

គ-អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី។

ឃ-ជនណាដែលត្រូវបានសង្ស័យ ឬ ត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលបានដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្តល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

[...]

៤. ការសម្រេចសេចក្ដីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប។

9. វិធាន ៦៩(២) នៃវិធានផ្ទៃក្នុងចែងថា៖

២. នៅពេលដែលគ្មានបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតត្រូវបិទសំណុំរឿងដោយមានបោះត្រាលើសំណុំរឿង និង៖

ក) ប្រសិនបើមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីកំណត់កាលបរិច្ឆេទសវនាការ។

ខ) ប្រសិនបើមានដីកាលើកលែងការចោទប្រកាន់ សំណុំរឿងត្រូវបានរក្សាទុកក្នុងបណ្ណាសារ ក្រោយផុតរយៈពេលធ្វើបណ្ដឹងឧទ្ធរណ៍។

10. វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងចែងត្រង់ផ្នែកពាក់ព័ន្ធថា៖“សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះតម្រូវឲ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម៤ (បួន) រូបយ៉ាងតិច។ សេចក្ដីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។”

11. វិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុងចែងថា៖

សេចក្ដីសម្រេចទាំងអស់ស្ថិតនៅក្នុងវិធាននេះ រួមទាំងគំនិតជំទាស់ផងត្រូវមានសំអាងហេតុ និងចុះហត្ថលេខាដោយចៅក្រមទាំងនោះ។ សេចក្ដីសម្រេចនេះ ត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងភាគីដទៃទៀតដោយក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ។ សហចៅក្រមស៊ើបអង្កេតត្រូវបន្តកិច្ចនីតិវិធីជាបន្ទាន់ស្របតាមសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

12. វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងចែងត្រង់ផ្នែកពាក់ព័ន្ធថា៖

អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្ដឹងសាទុក្ខ ជំទាស់ទៅនឹងសាលក្រមលើអង្គសេចក្ដី ឬសេចក្ដីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

ក. កំហុសលើអង្គច្បាប់ ដែលនាំឱ្យមោឃៈ សាលក្រមលើអង្គសេចក្ដី ឬសេចក្ដីសម្រេចនោះ។

ឬ

ខ. កំហុសនៃអង្គហេតុ ដែលនាំឱ្យសាលក្រមលើអង្គសេចក្ដី ឬ សេចក្ដីសម្រេចនោះមានភាពមិនយុត្តិធម៌។

បន្ថែមពីនេះ បណ្ដឹងសាទុក្ខភ្លាមៗ ប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអាចធ្វើទៅបានដោយផ្អែកលើមូលដ្ឋាននៃការភាន់ច្រឡំ ដែលស្ដែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខ។

13. វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុងចែងត្រង់ផ្នែកពាក់ព័ន្ធថា៖ “សេចក្ដីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង ដូចខាងក្រោមត្រូវបានបើកផ្លូវឱ្យប្ដឹងសាទុក្ខភ្លាមៗ៖ ក. សេចក្ដីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី [។] ”

14. វិធាន ១០៥(២) នៃវិធានផ្ទៃក្នុងចែងថា៖

ភាគីដែលមានបំណងប្ដឹងសាទុក្ខចំពោះសេចក្ដីសម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបើកផ្លូវសាទុក្ខភ្លាមៗ អនុលោមតាមវិធាន ១០៤(៤) ត្រូវដាក់បណ្ដឹងសាទុក្ខភ្លាមៗនេះ ដោយបញ្ជាក់ពីមូលដ្ឋានគាំទ្របណ្ដឹងសាទុក្ខ និងទឡ្ហីករណ៍នានា។ មូលដ្ឋាននីមួយៗនៃបណ្ដឹងសាទុក្ខត្រូវ៖

ក. បញ្ជាក់អំពីកំហុសអង្គច្បាប់ និងត្រូវបង្ហាញថាកំហុសនោះបណ្ដាលឱ្យសេចក្ដីសម្រេចមានមោឃភាព។ ឬ

ខ. បញ្ជាក់អំពីកំហុសដែលស្តែងឡើងពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។ ឬ

គ. បញ្ជាក់អំពីកំហុសអង្គហេតុ និងត្រូវបង្ហាញថាកំហុសនេះនាំឲ្យមានការភ័ន្តច្រឡំក្នុងការសម្រេចសេចក្តីរបស់តុលាការ។

15. វិធាន ១០៥(៤) នៃវិធានផ្ទៃក្នុងចែងថា៖ "រាល់បណ្តឹងសាទុក្ខត្រូវបង្ហាញផងដែរអំពីមូលដ្ឋាន ឬខ្លឹមសារនៃសេចក្តីសម្រេចដែលខ្លួនជំទាស់ដោយយោងលេខទំព័រ និងវាក្យខណ្ឌជាក់លាក់នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។"

## III. បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ

16. ដោយយោងតាម "បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ ជំទាស់ទៅនឹងសេចក្តីសម្រេចដូចមានចែងនៅក្នុងវិធាន១០៤(១) និង ១០៥(៤) អង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើការសម្រេចលើបណ្តឹងសាទុក្ខជាបន្ទាន់ ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖ (ក) កំហុសលើអង្គច្បាប់ដែលនាំឲ្យមោឃៈ សាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ។ (ខ) កំហុសនៃអង្គហេតុដែលនាំឲ្យសាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។ ឬ (គ) កំហុសដែលស្តែងឡើងពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ ស.ព.អ "។[7]

17. នៅពេលដែល អ.ជ.ត.ក ពិចារណាថាបណ្តឹងសាទុក្ខ មិនបានអនុលោមតាមបទប្បញ្ញត្តិនៃវិធាន ១០៤(៤)(ក) នោះនឹងរកឃើញថាបណ្តឹងសាទុក្ខមិនអាចទទួលយកបានឡើយ។[8] នៅក្នុងកាលៈ

---

[7] សំណុំរឿង ០០៤/២ *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារលេខ E004/2/1/1/2 (សេចក្តីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២), កថាខណ្ឌ ៣៦។

[8] សូមមើលសំណុំរឿង ០០២, *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីអញ្ញត្រកម្មរបស់លោក អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (Ne Bis in Idem) និងការលើកលែងទោស និងការអនុគ្រោះទោស)* ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ឯកសារលេខ E51/15/1/2 , ទំព័រ ២ (ដោយពិចារណាថា យុត្តិសាស្ត្រនៃ អ.ជ.ត.ក កំណត់ថា វិធាន ១០៤(៤)(ក) ពិចារណាតែអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចដែលមានឥទ្ធិពលនៃការបញ្ចប់ដំណើរការនីតិវិធី ផ្ទុយទៅនឹងសេចក្តីសម្រេចទាំងអស់ដែលទាក់ទងនឹងយុត្តាធិការរបស់ អ.វ.ត.ក។) សូមមើលសំណុំរឿង ០០២, *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង*

ទេសៈនេះ ទោះជាយ៉ាងណាក៏ដោយ អ.ជ.ត.ក បានរកឃើញថា បណ្តឹងសាទុក្ខអាចទទួលយកបាន - តែដោយគ្រាន់តែយោងទៅតាមយុត្តាធិការដែលមានជាប់មកជាមួយរបស់ខ្លួនប៉ុណ្ណោះ - ដើម្បីធានាថា សច្ចភាពផ្លូវច្បាប់ និងការបញ្ចប់ត្រូវទទួលបានក្នុងការកំណត់នៃរឿងក្តីនេះ និងបញ្ជាក់នូវសុចរិតភាពនៃស្ថាប័ន អ.វ.ត.ក។"[9]

18. នៅពេលដែលបណ្តឹងសាទុក្ខភ្លាមៗ ស្នើសុំ អ.ជ.ត.ក ឲ្យងាកចេញពីសេចក្តីសម្រេចពីមុន ផលប្រយោជន៍នៃសច្ចភាពផ្លូវច្បាប់ និងភាពអាចព្យាករណ៍បានតម្រូវឱ្យម្ចាស់បណ្តឹងសាទុក្ខបង្ហាញ "សំអាងហេតុត្រឹមត្រូវសមហេតុផលជាប្រយោជន៍យុត្តិធម៌"[10]។ ការងាកចេញគឺជា "ករណីលើកលែង" ចំពោះវិធានដែលសេចក្តីសម្រេចពីមុនត្រូវអនុវត្តតាម "ហើយអាចងាកចេញបានតែក្នុងករណីលើកលែង ហើយអាចធ្វើបែបនេះបាន បន្ទាប់ពីបានពិចារណាយ៉ាងយកចិត្តទុកដាក់បំផុតចំពោះសេចក្តីសម្រេចពីមុនៗ "ទាំងលើបញ្ហាអង្គច្បាប់ រួមទាំងឯកសារនានាដែលដកស្រង់មកធ្វើជាសំអាង និងបញ្ហាអង្គហេតុ [*sic*]""[11]។ ក្នុងករណីដែល សំអាងហេតុត្រឹមត្រូវសមហេតុផលអនុញ្ញាតឲ្យមានការងាកចេញ រួមបញ្ចូលនៅពេលដែលសេចក្តីសម្រេចនោះ "ត្រូវបានធ្វើឡើងដោយខុសឆ្គង ជាធម្មតាដោយសារចៅក្រមមួយរូប ឬច្រើនបានទទួលព័ត៌មានពុំត្រឹមត្រូវអំពីច្បាប់ជាធរមាន"។[12] ហេតុដូចនេះ នៅពេលដែល បណ្តឹងសាទុក្ខភ្លាមៗ ស្នើសុំ អ.ជ.ត.ក ឱ្យងាកចេញពីការសន្និដ្ឋាននៃច្បាប់របស់ខ្លួននៅក្នុងករណីមុនៗ វាត្រូវតែបង្ហាញថាមានកំហុសឲ្យច្បាស់លាស់

---

*សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ* ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ឯកសារលេខ E95/8/1/4, កថាខណ្ឌ ៨, ទំព័រ ២។

[9] សេចក្តីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២, កថាខណ្ឌ ៦៥។

[10] សំណុំរឿង ០០៣ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ ជុំ នៅ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារលេខ D11/3/4/2, មតិយោបល់របស់ ចៅក្រម Chung និងចៅក្រម Downing នៅកថាខណ្ឌ ១៦-១៧ ("មតិយោបល់របស់ចៅក្រម Chung និងចៅក្រម Downing")។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Aleksovski* (សំណុំរឿងលេខ IT-94-14/1-A), "សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍" ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ ១០៨។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Semanza* (សំណុំរឿងលេខ ICTR-97-20-A) "សេចក្តីសម្រេច" ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០ កថាខណ្ឌ ៩២។

[11] មតិយោបល់របស់ ចៅក្រម Chung និងចៅក្រម Downing កថាខណ្ឌ ១៧ (ការដកស្រង់ខាងក្នុង ត្រូវបានលុបចោល)។

[12] មតិយោបល់របស់ ចៅក្រម Chung និងចៅក្រម Downing កថាខណ្ឌ ១៦ (ការដកស្រង់ខាងក្នុង ត្រូវបានលុបចោល)។

នៅសំអាងហេតុរបស់ អ.ជ.ត.ក ឬ ការផ្លាស់ប្តូរនៅក្នុងកាលៈទេសៈដែលតម្រូវឱ្យ អ.ជ.ត.ក មានសេចក្តីសម្រេចខុសគ្នា។[13]

19. “រាល់ទឡ្ហីករណ៍របស់ភាគីទាំងឡាយណាដែល គ្មានសក្តានុពលបង្កឱ្យមានការកែប្រែ ឬ បង្កឱ្យមានការកែសម្រួលដីកាសម្រេចដែលរងការជំទាស់ទេនោះ អាចនឹងត្រូវបានបដិសេធចោលភ្លាមៗដោយអង្គជំនុំជម្រះតុលាការកំពូលហើយក៏មិនចាំបាច់ត្រូវធ្វើការពិចារណាលើអង្គសេចក្តីដែរ។”[14] ទឡ្ហីករណ៍បែបនេះរួមមាន៖ (i)ទឡ្ហីករណ៍ដដែលៗ ដែលគ្មានការបង្ហាញអំពីមូលហេតុនៃការបដិសេធរបស់ខ្លួនបង្កើតជាកំហុស[15] (ii)ទឡ្ហីករណ៍ដែល “ទទួលរងនូវភាពមិនគ្រប់គ្រាន់ដទៃទៀតតាមទម្រង់ការ និងដោយជាក់ស្តែង”[16] និង (iii)“ទឡ្ហីករណ៍ដែលមិនជាប់ពាក់ពន្ធ័យ៉ាងច្បាស់”។[17]

## IV. ភាពដែលអាចទទួលយកបាន

### i. បណ្តឹងសាទុក្ខរបស់ ស.ព.អ មិនអាចទទួលយកបានទេ ដោយសារ ស.ច.ស មានយុត្តាធិការផ្តាច់មុខលើសំណុំរឿង ០០៤

---

[13] សំណុំរឿង ០០២ *សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យពិចារណាឡើងវិញនូវសេចក្តីសម្រេចអំពីការស្នើសុំបន្ថែមពេលវេលានិងចំនួនទំព័រលើសេចក្តីជូនដំណឹង អំពីបណ្តឹងសាទុក្ខ* ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ ឯកសារលេខ F44/1 ទំព័រ២។ សំណុំរឿង០០២ *សេចក្តីសម្រេចលើសារណារបស់សហព្រះរាជអាជ្ញាស្តីពីកិច្ចដំណើរការនីតិវិធីជាមួយនឹងសវនាការលើបណ្តឹងសាទុក្ខ* ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារលេខ F30/16/1 ទំព័រ ៣។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Šešelj,* សំណុំរឿងលេខ IT-03-67-AR72.1, “សេចក្តីសម្រេចលើញត្តិសុំពិចារណាឡើងវិញនូវ “សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំ ពាក់ពន្ធ័នឹងអញ្ញត្រកម្មយុត្តាធិការ” ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៤” ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៦ កថាខណ្ឌ ៩។

[14] សំណុំរឿង ០០១ *សាលដីកាសម្រេចលើបណ្តឹងសាទុក្ខ* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារលេខ F28 (“សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១”) កថាខណ្ឌ ២០។

[15] សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១, កថាខណ្ឌ ២០។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Stanišić និង Simatović* សំណុំរឿងលេខ IT-03-69-A “សាលដីកា” ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ២២។

[16] សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១, កថាខណ្ឌ ២០។

[17] អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Stanišić និង Simatović* សំណុំរឿងលេខ IT-03-69-A “សាលដីកា” ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ២២។

20. ស.ព.អ ស្នើសុំ អ.ជ.ត.ក ដោយខុសឆ្គង ឲ្យទទួលយកថាបណ្តឹងសាទុក្ខរបស់ ស.ព.អ ស្ថិតក្រោមយុត្តាធិការដែលមានជាប់មកជាមួយ និងបញ្ជាឲ្យបញ្ជូនសំណុំរឿង ០០៤ ទៅ អ.ជ.ស.ដ ដើម្បីជំនុំជម្រះ។[18] ការធ្វើដូចនេះ ស.ព.អ មិនទទួលស្គាល់ថា ស.ច.ស ទទួលយកសំណុំរឿង ០០៤ និង មានយុត្តាធិការផ្តាច់មុខ។

21. វាជាមូលដ្ឋានគ្រឹះនៃរចនាសម្ព័ន្ធរបស់ អ.វ.ត.ក ដែលសេចក្តីសម្រេចរបស់ អ.ប.ជ មិនមែនជាកម្មវត្ថុនៃការប្តឹងសាទុក្ខទៅ អ.ជ.ត.ក ដូចដែលបានចែងនៅក្នុងវិធាន ៧៧(១៣)។ ជាពិសេសនៅក្នុងផ្នែកសេចក្តីសម្រេចជាឯកច្ឆន្ទ នៃសេចក្តីពិចារណារបស់ អ.ប.ជ ចៅក្រមទាំងអស់បានសម្រេច(ជាឯកច្ឆន្ទ)ថា "សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា"។[19] ជាងនេះទៅទៀត សេចក្តីពិចារណារបស់ អ.ប.ជ មិនមែនជាសេចក្តីសម្រេច ឬ សាលក្រមរបស់ អ.ជ.ស.ដ ដែលអាចប្តឹងឧទ្ធរណ៍បានស្ថិតនៅក្រោមវិធាន ១០៤(៤)(ក) ឬ វិធាន ១០៥(៤) ដែលគ្មានមូលដ្ឋាន ណាមួយ របស់ ស.ព.អ នៅមូលដ្ឋាន ក, ខ, គ និង ឃ អាចទទួលយកបាន ដោយផ្អែកលើនីតិវិធីដែលមានចែងក្នុងវិធានផ្ទៃក្នុងឡើយ។

22. ទោះជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីទទួលស្គាល់យុត្តាធិការដែលមានជាប់មកជាមួយរបស់ អ.ជ.ត.ក ដើម្បីបញ្ចប់ដំណើរការនីតិវិធី នៅក្នុងកាលៈទេសៈដែលមានកំណត់។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួននៅក្នុងសំណុំរឿង ០០៤/២ អ.ជ.ត.ក បានសម្រេចថា បណ្តឹងសាទុក្ខរបស់ ស.ព.អ មិនអាចទទួលយកបាន អនុលោមតាមវិធាន១០៤(៤)(ក) និង វិធាន ១០៥(៤)។[20] អ.ជ.ត.ក បានសម្រេចចិត្តប្រើឆន្ទានុសិទ្ធិរបស់ខ្លួន "ដើម្បីផលប្រយោជន៍នៃយុត្តិធម៌ និងភាពត្រឹមត្រូវ ហើយទទួលយកបណ្តឹងសាទុក្ខនេះ ដើម្បីធានាបាននូវសច្ចភាពផ្លូវច្បាប់ និងការបញ្ចប់"[21]

---

[18] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១១-១៦, ៣១-៣៥, ៧៤។

[19] សេចក្តីពិចារណារបស់ អ.ប.ជ កថាខណ្ឌ ៤៩។

[20] សេចក្តីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២, កថាខណ្ឌ ៥៧ និង៦៥។

[21] សេចក្តីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២, កថាខណ្ឌ ៤០,៤២,៤៤,៥៨ និង៦០។ អ.ជ.ត.ក បានធ្វើដូច្នេះនៅលើមូលដ្ឋានយុត្តាធិការដែលបានស្នើសុំដោយ ស.ព.អ (ស.ព.អ បានស្នើសុំឲ្យ អ.ជ.ត.ក "ដោះស្រាយបញ្ហាអង្គច្បាប់មុនពេលវាមានលក្ខណៈច្បាស់លាស់" និង"អនុវត្តយុត្តាធិការដែលមានជាប់មកជាមួយរបស់ខ្លួនដើម្បីសម្រេចថាបណ្តឹងឧទ្ធរណ៍អាចទទួលយកបានដោយផ្អែកលើមូលដ្ឋានដែល"មានតម្រូវការចាំបាច់ដើម្បីធានាឱ្យមានការគ្រប់គ្រងល្អ និងយុត្តិធម៌" ខណៈពេលដែលមេធាវីការពារក្តី អោ អាន មិនគាំទ្រការអនុវត្តយុត្តាធិការដែលមានជាប់មកជាមួយរបស់ អ.ជ.ត.ក)។

នៅក្នុងកាលៈទេសៈដែល ស.ច.ស មិនដំណើរការពេញលេញ ហើយវាមិនច្បាស់ថាស្ថាប័នណាមួយដែលអាចទទួលយកសំណុំរឿង ០០៤/២ បន្ទាប់ពីសេចក្តីពិចារណារបស់ អ.ប.ជ ។

23. កត្តាចាំបាច់ដែលដាក់កាតព្វកិច្ចឱ្យ អ.ជ.ត.ក ឱ្យធានាបាននូវសច្ចភាពផ្លូវច្បាប់ និងការបញ្ចប់ត្រូវទទួលបានក្នុងការសម្រេចនៃសំណុំរឿង០០៤/២ មិនមាននៅក្នុងសំណុំរឿង ០០៤ នោះទេ។[22]

24. ស.ព.អ បំភាន់ អ.ជ.ត.ក ដោយការជ្រើសរើសតែសំអាងហេតុដែលគាំទ្របណ្តឹងរបស់ខ្លួន ពីក្នុងសេចក្តីពិចារណារបស់ អ.ប.ជ ហើយលុបចេញពីសារណារបស់ខ្លួនទៅ អ.ជ.ត.ក ចំពោះការណ៍ដែល អ.ប.ជ យល់ឃើញថាចាប់ពីការចេញសេចក្តីពិចារណាទាំងនោះ គឺ ស.ច.ស ត្រូវទទួលយកសំណុំរឿង ០០៤។[23] អ.ប.ជ ជាឯកច្ឆន្ទ "បានប្រកាសថា ការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ដែលរំលោភបំពានក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក" ដោយយល់ឃើញថា "ស.ច.ស មានភារកិច្ចតាមផ្លូវតុលាការក្នុងការសម្រេចលើបញ្ហាដែលមានវិវាទ ដែលពួកគាត់បានទទួល"[24]។ អ.ប.ជ បានបញ្ជាក់ទៀតថា "ក្នុងករណីដែលការខ្វែងយោបល់គ្នារបស់ពួកគាត់ រារាំងពួកគាត់មិនឱ្យឈានទៅដល់ការសម្រេចជាស្ថាពររួមគ្នាទៅលើបញ្ហាបែបនេះ ពួកគាត់នៅតែចាំបាច់ត្រូវបញ្ចប់ ភារកិច្ចតាមផ្លូវតុលាការរួមគ្នានេះដោយគោរពទៅតាមនីតិវិធីជាធរមាននៅក្នុងប្រព័ន្ធច្បាប់ អ.វ.ត.ក ដើម្បីធានាថា អាចឈានដល់ការសម្រេចរួមទៅលើបញ្ហាដែលស្ថិតក្នុងយុត្តាធិការរបស់ពួកគាត់"[25]។ អានុភាពផ្លូវច្បាប់នៃការយល់ឃើញនេះ ត្រូវបានបញ្ជាក់បំភ្លឺនៅក្នុងសំណុំរឿង០០៣ ដែល អ.ប.ជ បានសម្រេចថាក្រោយជូនដំណឹង "ផ្នែកនៃសេចក្តីសម្រេចនៅក្នុងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ" ស.ច.ស "ទទួលខុសត្រូវដំណើរការសំណុំរឿងនេះ។"[26] អ.ប.ជ បានរកឃើញថាការឱ្យ ស.ច.ស ចាត់ការ

[22] សេចក្តីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២, កថាខណ្ឌ ៦៥។

[23] សេចក្តីពិចារណាលើសំណុំរឿង ០០៤ ទំព័រ ៤៩។

[24] សេចក្តីពិចារណាលើសំណុំរឿង ០០៤ ទំព័រ ៤៩ កថាខណ្ឌ ១១១។

[25] សេចក្តីពិចារណាលើសំណុំរឿង ០០៤ កថាខណ្ឌ ១១១។

[26] សំណុំរឿង ០០៣ *សេចក្តីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីការពារក្តី មាស មុត ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣* ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ ឯកសារលេខ D271/5 និង D272/3 ("សេចក្តីសម្រេចរួមក្នុងសំណុំរឿង ០០៣") កថាខណ្ឌ ៧២។

ឡើងវិញ“នឹងធ្វើឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតមានសមត្ថភាពបំពេញមុខងាររបស់ខ្លួន គឺមិនដូចគ្នាបន្ទាប់ពីចេញសេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ នោះទេ។”[27]

25. ការមើលរំលង ការយល់ឃើញរបស់ អ.ប.ជ, ស.ព.អ បានអះអាងដោយបំភាន់ ថា ដោយផ្អែកលើយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតថា សំណុំរឿង០០៤ គឺស្ថិតក្នុងកាលៈទេសៈនីតិវិធីស្រដៀងនឹងសំណុំរឿង ដែលពុំមានតុលាការណាមួយមានអំណាច ប្រកាសលើបញ្ហានោះដោយសារ “ការរាំងស្ទះផ្លូវច្បាប់ ឬ ឧបសគ្គផ្នែកអនុវត្ត” ហើយវាចាំបាច់ដែលត្រូវដោះស្រាយនូវចន្លោះប្រហោង ដែលអាចមានក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ ឬ ដើម្បីធានាថា យុត្តិធម៌មិនត្រឹមតែធ្វើបានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានគេ*មើលឃើញថា* សម្រេចបានផងដែរ។[28] ការអនុវត្តអន្តរជាតិនេះគួរតែត្រូវបានបន្ធូរបន្ថយដោយ អ.ជ.ត.ក ដោយសារតែគ្មានកាលៈទេសៈនីតិវិធីទាំងនេះណាមួយ អនុវត្តចំពោះសំណុំរឿង ០០៤ នោះទេ។[29]

26. ស.ព.អ ក៏បានលើកឡើងដែរថា អ.ជ.ត.ក គួរតែធ្វើសកម្មភាពដោយមិនចាំបាច់ប្រើប្រាស់ដំណោះស្រាយនានាឲ្យអស់លទ្ធភាព ដូចដែលបានកំណត់ដោយក្របខ័ណ្ឌគតិយុត្តិ អ.វ.ត.ក។[30] ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួន ស.ព.អ បានលើកឡើងពីនីតិវិធីនៃ តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR) តុលាការសិទ្ធិមនុស្សអន្តរអាមេរិកកាំង (IACtHR) តុលាការកំពូលអាមេរិក (USSC) ដោយមិនបានពន្យល់ថាតើ ប្រភពទាំងនេះ អនុវត្តចំពោះដំណើរការនៅ អ.វ.ត.ក យ៉ាងដូចម្តេច។[31] វិធានច្បាប់ និងគោលការណ៍ដែលបានបង្កើតឡើងដោយ តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR) តុលាការសិទ្ធិមនុស្សអន្តរអាមេរិកកាំង (IACtHR) និង តុលាការកំពូលអាមេរិក (USSC) មានទំនាក់ទំនងជាមួយនឹងការប្រើប្រាស់ដំណោះស្រាយឲ្យអស់លទ្ធភាព ដែលដំណោះស្រាយ

---

[27] សេចក្តីសម្រេចរួមក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៧២។

[28] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១៥ (សង្កត់ន័យបន្ថែមនៅក្នុងឯកសារដើម)។

[29] មិនមាន“ការរាំងស្ទះផ្លូវច្បាប់ ឬ ឧបសគ្គផ្នែកអនុវត្ត” ដោយសារតែ សហចៅក្រមស៊ើបអង្កេតមាន ដំណើរការពេញលេញដោយមានសហចៅក្រមស៊ើបអង្កេតជាតិម្នាក់ (ស.ច.ស.ជ) ជាមួយនឹង សហចៅក្រមស៊ើបអង្កេតអន្តរជាតិម្នាក់(ស.ច.ស.អ) និង បុគ្គលិកផ្នែកច្បាប់ ហើយវាមានដំណើរការប្រក្រតីក្នុងការសម្រេចលើសំណើសុំរបស់មេធាវីការពារក្តី ដោយអនុលោមតាមយុត្តាធិការផ្តាច់មុខរបស់ខ្លួន។

[30] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១៦។

[31] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១៦។ ស.ព.អ បានប្រើប្រាស់ទំនាក់ទំនងរបស់ ECtHR និង IACtHR ចំពោះរដ្ឋជាសមាជិករបស់ពួកគេ និងទំនាក់ទំនងរបស់តុលាការសហព័ន្ធសហរដ្ឋអាមេរិកចំពោះតុលាការរបស់រដ្ឋ។

ទាំងនេះមិនអាចអនុវត្តបាននោះទេ ដោយសារតែក្របខ័ណ្ឌគតិយុត្តិ អ.វ.ត.ក កំណត់យុត្តាធិការរបស់អង្គជំនុំជម្រះក្នុង អ.វ.ត.ក និងផ្តល់យុត្តាធិការផ្តាច់មុខរបស់ ស.ច.ស លើបញ្ហាដែលពួកគេបានទទួលយក។[32] ម៉្យាងវិញទៀត ការដាក់ស្នើរបស់ ស.ព.អ គឺគ្មានមូលដ្ឋាន។ ដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤ មិនទាន់ប្រើប្រាស់អស់លទ្ធភាពនៅឡើយទេ ដោយសារ ស.ច.ស មានយុត្តាធិការផ្តាច់មុខ និងបានទទួលយកសំណើរបស់មេធាវីការពារក្តីដាក់ស្នើទៅ ស.ច.ស។[33] កាលៈទេសៈនីតិវិធីនៃសំណុំរឿង ០០៤ មិនមានលក្ខណៈស្រដៀងគ្នាទៅនឹង កាលៈទេសៈនីតិវិធីដែលបានយោងនៅក្នុងយុត្តិសាស្ត្រសហរដ្ឋអាមេរិក នៅក្នុងរឿងក្តី Mullins Coal Co ទល់នឹង Clark ឡើយ។[34] ស.ព.អ ខកខានមិនបានពន្យល់ពីរបៀបក្នុងការប្រើប្រាស់ដំណោះស្រាយរបស់គាត់ នៅក្នុងចម្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តីស្នើទៅ ស.ច.ស ឬ នៅក្នុងបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងសេចក្តីសម្រេចដែលមានសក្តានុពលពី ស.ច.ស ឲ្យក្លាយជា "កាយវិការឥតប្រយោជន៍"។[35] ផ្ទុយពីអំណះអំណាងរបស់ ស.ព.អ អំពី "ការប្រើប្រាស់ដំណោះស្រាយឲ្យអស់លទ្ធភាព" គឺមិនមាន "ករណីលើកលែង" ចេញពីនីតិវិធីដែលអនុវត្តបាននៅ អ.វ.ត.ក៖ សហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) គឺកំពុងដំណើរការយ៉ាងពេញលេញ និងមានយុត្តាធិការផ្តាច់មុខក្នុងការសម្រេចចិត្តលើញត្តិដែលពុំទាន់សម្រេចនៅក្នុងសំណុំរឿង០០៤ ដូចដែលបានលើកឡើងខាងលើ។

---

[32] វិធាន ៦៩(២)(ខ) បានផ្តល់ឲ្យ ស.ច.ស នូវយុត្តាធិការផ្តាច់មុខដើម្បីបញ្ជូនសំណុំរឿងទៅ អ.ជ.ស.ដ ឬ បោះត្រា និងដាក់បញ្ចូលទៅក្នុងបណ្ណសារ។ វិធាន ៧៧(១៤) បានចែងថារាល់សេចក្តីសម្រេចទាំងអស់របស់ អ.ប.ជ "ត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត" ហើយសហចៅក្រមស៊ើបអង្កេតត្រូវបន្តកិច្ចនីតិវិធី ជាបន្ទាន់ស្របតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

[33] ដូចមានខាងលើ កថាខណ្ឌ ២០-២៥។

[34] *Mullins Coal Co ទល់នឹង Clark*, 759 F.2d 1142, 1146 (4th Cir 1985) ដកស្រង់នៅក្នុង បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១៦។

[35] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣២ និង ៣៣។ សូមមើលផងដែរ *Mullins Coal Co ទល់នឹង Clark*, 759 F.2d 1142, 1146 (4th Cir 1985) (ដែលសម្រេចថា "បណ្តឹងវិវាទមិនចាំបាច់ត្រូវការដំណោះស្រាយរដ្ឋបាលឲ្យអស់លទ្ធភាពនោះទេ នៅក្នុងករណីដែលការស្វែងរករបស់ខ្លួននឹងទៅជាកាយវិការឥតប្រយោជន៍")។

### ii. បណ្តឹងសាទុក្ខរបស់ ស.ព.អ មិនអាចទទួលយកបានទេ ដោយសារវាស្វែងរកការដោះស្រាយឡើងវិញនូវបញ្ហាពីក្នុងសំណុំរឿង ០០៤/២ យកមកធ្វើជាចំណុចវិវាទសារជាថ្មី

27. អង្គច្បាប់ នៅក្នុងមូលដ្ឋាន ក, ខ និង គ ត្រូវបានសម្រេចដោយ អ.ជ.ត.ក រួចមកហើយនៅក្នុងសំណុំរឿង ០០៤/២។ ស.ព.អ មិនបានបង្ហាញពី សំអាងហេតុត្រឹមត្រូវសមហេតុផល ដើម្បីឱ្យ អ.ជ.ត.ក ងាកចេញពីសេចក្តីសម្រេចដែលបានសម្រេចរួចហើយនៅក្នុងសំណុំរឿង ០០៤/២ ហើយមិនបានបង្កើតការភាន់ច្រឡំលើអង្គច្បាប់ ឬ ការផ្លាស់ប្តូរកាលៈទេសៈដែលអាចធ្វើឱ្យ អ.ជ.ត.ក ពិនិត្យមើលអង្គច្បាប់ទាំងនេះឡើងវិញនោះទេ។[36]

28. នៅក្នុងមូលដ្ឋាន ក, ស.ព.អ ស្វែងរកការដោះស្រាយឡើងវិញដែលមិនត្រូវបានអនុញ្ញាតនូវបញ្ហាដែលបានចោទសួរថាតើដីកាដំណោះស្រាយផ្ទុយគ្នាខុសច្បាប់ឬយ៉ាងណា យកមកធ្វើជាចំណុចវិវាទសារជាថ្មី។[37] អ.ជ.ត.ក បានសម្រេចថា "ដោយផ្អែកលើការយល់ឃើញរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ដែលថា ការបំពេញកិច្ចរបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ មានន័យថា ពុំមានដីកាដំណោះស្រាយណាមួយមានសុពលភាពឡើយ"[38]។ ប្រសិនបើ អ.ជ.ត.ក មិនយល់ស្របនឹងការយល់ឃើញរបស់ អ.ប.ជ ទេ នោះនឹងមានការកែប្រែកំហុសដោយសារ អ.ជ.ត.ក មានអំណាចក្នុងការក្នុងការ "លើកបញ្ហាឡើង *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* 'raise questions *ex proprio motu*' ដែលបញ្ហាអង្គច្បាប់គឺមានសារៈសំខាន់ទូទៅចំពោះយុត្តិសាស្ត្ររបស់ អ.វ.ត.ក។"[39] ស.ព.អ បានត្រឹមលើកអំណះអំណាងដដែលៗ ដែលខ្លួនបានធ្វើនៅចំពោះមុខ អ.ប.ជ ដែលថាវិធាន ១(២) បានផ្តល់មូលដ្ឋានច្បាប់សម្រាប់ ស.ច.ស ដើម្បីចេញដីកាដំណោះស្រាយចំនួនពីរ[40] ដែល អ.ប.ជ បានច្រានចោលការចេញដីកាដំណោះស្រាយផ្ទុយគ្នា

---

[36] ដូចមានខាងលើ កថាខណ្ឌ ១៨-១៩។

[37] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣៦-៤៤។

[38] សេចក្តីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៧១(v)។

[39] សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១, កថាខណ្ឌ ១៥ និង ១៦។

[40] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៤១ ការអះអាងឡើងវិញនូវអំណះអំណាងដែលបានធ្វើឡើងនៅក្នុង *បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ (D381)* ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារលេខ D381/19 កថាខណ្ឌ ១៧៣។

នៅគ្រប់កាលៈទេសៈទាំងអស់[41] ទោះបីជាបន្ទាប់ពី អ.ជ.ត.ក បានជំរុញឱ្យ អ.ប.ជ បញ្ជាក់ពីទស្សនៈរបស់ខ្លួនលើវិធាន ១(២) ក៏ដោយ។[42]

29. នៅក្នុងមូលដ្ឋាន ខ, ស.ព.អ ស្វែងរកការដោះស្រាយឡើងវិញដែលមិនត្រូវបានអនុញ្ញាតនូវបញ្ហាដែលបានចោទសួរថាតើដីកាដំណោះស្រាយត្រូវចាត់ទុកជាមោឃៈ និងគ្មានសុពលភាព ទោះបីជាការចេញក្នុងពេលដំណាលគ្នារបស់វា គឺខុសច្បាប់ក៏ដោយ។[43] នេះមិនមែនជាបញ្ហានោះទេ ដូចដែល អ.ជ.ត.ក បានទទួលស្គាល់យ៉ាងច្បាស់លាស់។[44] ការប៉ុនប៉ងដែលវៀចវេរ ក្នុងការបែងចែករវាងដីកាដំណោះស្រាយដែលត្រូវបានចេញដោយខុសច្បាប់ និងប្រសិទ្ធភាពផ្លូវច្បាប់របស់វា គឺជាការពិចារណាបែបបំភាន់យ៉ាងច្បាស់ក្រឡែត។

30. នៅក្នុងមូលដ្ឋាន គ, ស.ព.អ ស្វែងរកការដោះស្រាយឡើងវិញដែលមិនត្រូវបានអនុញ្ញាតនូវបញ្ហាដែលបានចោទសួរថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានបដិសេធដោយសំឡេងគាំទ្រច្រើនលើសលុបដែរឬទេ ដូច្នេះសំណុំរឿងត្រូវបញ្ជូនទៅជំនុំជម្រះ។[45] អ.ជ.ត.ក បានកំណត់រួចហើយនៅក្នុងសំណុំរឿង ០០៤/២ ថាប្រសិនបើគ្មានការ ចេញនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយស្របច្បាប់នោះ វាគ្មានមូលដ្ឋានដើម្បីបញ្ជូនសំណុំរឿងទៅជំនុំជម្រះនោះទេ។[46] ដោយការព្យាយាមធ្វើដូច្នេះ ដោយយោងតាមសេចក្ដីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២ ស.ព.អ "គេចវេស ឬ មិនអើពើអំពីផលវិបាកនៃការយល់ឃើញជា*ឯកច្ឆន្ទ* របស់អង្គបុរេជំនុំជម្រះ

[41] សំណុំរឿង ០០៤/២ *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារលេខ D359/24 និង D360/33 កថាខណ្ឌ ១២១។ សំណុំរឿង ០០៣ *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ ឯកសារលេខ D266/27 និង D267/35 កថាខណ្ឌ ១០៣ និង ១០៤។ សេចក្ដីពិចារណាលើសំណុំរឿង ០០៤ កថាខណ្ឌ ១០៩ និង ១១០។

[42] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៦៨ ចែងថា ("ទោះវិធានអនុញ្ញាតឱ្យចៅក្រមស៊ើបសួរធ្វើសកម្មភាពជាលក្ខណៈបុគ្គល ក៏នៅតែត្រូវដោះស្រាយដោយអង្គបុរេជំនុំជម្រះ។")

[43] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៤៥-៥១។

[44] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៦៧។ អ.ជ.ត.ក បានទទួលស្គាល់ថាដោយសារតែភាពមិនអាចអនុញ្ញាតបាននៃការចេញដីកាដំណោះស្រាយផ្ទុយគ្នានោះ មិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះស្របច្បាប់នៅពេលដែលមានដីកាដំណោះស្រាយពីរត្រូវបានចេញនោះទេ។

[45] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥២-៥៧។

[46] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៦៧។

ដែលថាដីកាដំណោះស្រាយគឺជាលទ្ធផលនៃចំណាត់ការ*ខុសច្បាប់ និងមិនត្រឹមត្រូវតាមច្បាប់*។[47] មិនមានបញ្ហាផ្ទាល់ក្នុងសំណុំរឿង ០០៤ ថាតើដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានបដិសេធដោយ អ.ប.ជ ស្របតាមសំឡេងគ្រាំទ្រច្រើនលើសលុបឬទេ ដោយសារនៅក្នុងសំណុំរឿង ០០៤ អ.ប.ជ បានសម្រេច*ជាឯកច្ឆន្ទ* ថាការចេញដីកាដំណោះស្រាយចំនួនពីរ គឺខុសច្បាប់ហើយលទ្ធផលនៃសេចក្តីសម្រេចនេះគឺដូចគ្នាទៅនឹងសំណុំរឿង ០០៤/២ ដែរ៖ ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានចេញដោយខុសច្បាប់គឺមិនមានអត្ថិភាពនោះទេ។[48]

31. ដូចដែលមានកត់សម្គាល់ដោយ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២ ស.ព.អ បានស្នើសុំយ៉ាងច្បាស់លាស់នូវ សេចក្តីសម្រេចចុងក្រោយរបស់ អ.ជ.ត.ក ចំពោះបណ្តឹងសាទុក្ខភ្លាមៗរបស់ខ្លួនថា "យុត្តិសាស្ត្រដែលមានសំអាងហេតុពេញលេញគឺជាការចាំបាច់ ដោយសារកាលៈទេសៈនៃនីតិវិធីប្រហាក់ប្រហែលគ្នាដែលមានសក្តានុពលទំនងនឹងមានអត្ថិភាពនៅក្នុងសំណុំរឿង ០០៣ និង ០០៤។"[49] ដោយបានឃើញពីជំហររបស់ ស.ព.អ នៅក្នុងសំណុំរឿង ០០៤/២ ការប៉ុនប៉ងជាថ្មីរបស់ ស.ព.អ ក្នុងសំណុំរឿង ០០៤ (និងសំណុំរឿង ០០៣[50]) ស្វែងរកការដោះស្រាយឡើងវិញនូវបញ្ហាដែលត្រូវបានសម្រេចម្តងរួចមកហើយមកធ្វើជាចំណុចវិវាទសារជាថ្មីនិងដើម្បីឱ្យ អ.ជ.ត.ក បដិសេធគោលជំហររបស់ខ្លួនពីមុន គឺត្រូវបានបង្ហាញថាជា*ការផ្លាស់ប្តូរទាំងស្រុង (volte face)* ដោយភាពវៀចវេររបស់ ស.ព.អ។ ស.ព.អ មិនផ្តល់សំអាងហេតុត្រឹមត្រូវសមហេតុផល អង្គច្បាប់ថ្មី ឬការផ្លាស់ប្តូរកាលៈទេសៈសម្រាប់ អ.ជ.ត.ក ដើម្បីស្តាប់អំណះអំណាងលើបញ្ហាទាំងនោះម្តងទៀតនោះទេ។[51]

---

[47] ដូចមានខាងលើ (សង្កត់ន័យបន្ថែមនៅក្នុងឯកសារដើម)។

[48] សេចក្តីពិចារណាលើសំណុំរឿង ០០៤ ទំព័រ ៩៩។ ក្នុងន័យនេះ មូលដ្ឋាន គ គឺជាការពិចារណារងនៃ មូលដ្ឋាន ខ ដែលត្រូវបានលុបចោលដោយ មូលដ្ឋាន ក។

[49] សេចក្តីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៤២ ដោយដកស្រង់សំណុំរឿង ០០៤/២ *បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ ឯកសារលេខ E004/2/1 កថាខណ្ឌ ៤៨, ៥៨-៦១។

[50] សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ មាស មុត សុំបញ្ចប់សំណុំរឿង ០០៣ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ ឯកសារលេខ ៤/១។

[51] ដូចមានខាងលើ កថាខណ្ឌ ១៨-១៩។

## V. ចម្លើយតប

### i. ស.ព.អ ស្នើសុំដំណោះស្រាយដែលត្រូវបានបដិសេធនៅក្នុងសំណុំរឿង ០០៤/២

32. ស.ព.អ បានស្នើសុំ អ.ជ.ត.ក ឲ្យអនុវត្តមូលដ្ឋានច្បាប់ដែលត្រូវបានបដិសេធនៅក្នុងសំណុំរឿង ០០៤/២[52]។ ទោះបីជាមានការស្នើសុំដំណោះស្រាយដូចគ្នា ដែលត្រូវបានបដិសេធដោយ អ.ជ.ត.ក នៅក្នុងសេចក្តីសម្រេចដោយមានសំអាងហេតុនៅក្នុងសំណុំរឿង ០០៤/២[53] ក្តីក៏ ស.ព.អ មិនបានផ្តល់ "សំអាងហេតុត្រឹមត្រូវសមហេតុផល" ដើម្បីងាកចេញពីសេចក្តីសម្រេចនោះឡើយ[54]។ ពុំមានការភាន់ច្រឡំលើអង្គច្បាប់នៅក្នុងសំអាងហេតុរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២ ឬ ការផ្លាស់ប្តូរកាលៈទេសៈដែលអាចជាយុត្តិកម្ម ដើម្បីអោយ អ.ជ.ត.ក អនុវត្តខុសគ្នានៅក្នុងសំណុំរឿង ០០៤ឡើយ។

33. នៅក្នុងករណីដែល អ.ជ.ត.ក រកឃើញថា បណ្តឹងសាទុក្ខរបស់ ស.ព.អ អាចទទួលយកបាន ក៏មូលដ្ឋានទាំងអស់នៃបណ្តឹងសាទុក្ខត្រូវតែបដិសេធ ដោយសារ៖ (i).មូលដ្ឋាន ក, ខ និង គ គឺ ស.ព.អ មានកំហុសដោយមិនទទួលស្គាល់ថាការចេញដីកាដំណោះស្រាយចំនួនពីរគឺខុសច្បាប់ ដូចនេះ ដីកាដំណោះស្រាយទាំងពីរត្រូវចាត់ទុកថាមោឃៈ និង គ្មានសុពលភាព៖ និង (ii). នៅក្នុងមូលដ្ឋាន ឃ, ស.ព.អ បានដាក់បណ្តឹងសាទុក្ខដោយមិនត្រឹមត្រូវចំពោះ មតិដាច់ដោយឡែករបស់ អ.ប.ជ ដែលមាន"ភាពមិនពាក់ពន្ធ័"។

### ii.មូលដ្ឋាន ក, ខ និង គ៖ ស.ព.អ មានកំហុសដោយមិនទទួលស្គាល់ថាការចេញដីកាដំណោះស្រាយចំនួនពីរគឺខុសច្បាប់ ដូចនេះដីកាដំណោះស្រាយទាំងពីរត្រូវចាត់ទុកថាមោឃៈ និងគ្មានសុពលភាព

34. នៅក្នុងមូលដ្ឋាន ក, ខ និង គ, ស.ព.អ បានអះអាងដោយមិនត្រឹមត្រូវថាសំណុំរឿង ០០៤ ត្រូវតែបញ្ជូនទៅជំនុំជម្រះ ដោយយោងតាមគោលជំហរស្វ័យប្រវត្តិ ពីព្រោះ៖ (i) ដីកាដំណោះស្រាយមិនត្រូវបានចេញដោយខុសច្បាប់នោះទេ (ii)"ប្រសិនបើ*សម្រាប់គោលបំណងវែកញែក (arguendo)*

---

[52] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ២-៥។

[53] សំណុំរឿង ០០៤/២ *បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ ឯកសារលេខ E004/2/1 កថាខណ្ឌ៤៨, ៥៨-៦១។

[54] ដូចមានខាងលើ កថាខណ្ឌ ១៨-១៩។

ការចេញក្នុងពេលដំណាលគ្នារបស់វា គឺខុសច្បាប់" ការណ៍ធ្វើបែបនេះ មិនត្រូវបានចាត់ទុកថា មោឃៈ និង គ្មានសុពលភាព ឡើយ និង (iii)ការបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានបដិសេធ ដោយ អ.ប.ជ ដោយសំឡេងគ្រាំទ្រច្រើនលើសលុបឡើយ។[55] ដូចដែលមេធាវីការពារក្ដីបានផ្ដល់អំណះអំណាងនៅចំពោះមុខ អ.ជ.ត.ក រួចមកហើយ នៅពេលដែលមេធាវីការពារក្ដីស្វែងរកការធ្វើអន្តរាគមន៍នៅក្នុងសំណុំរឿង០០៤/២ នៅពេលនោះ មិនមានបញ្ហាថាតើ "ផលប៉ះពាល់" ឬ "ផលវិបាក" នៃសេចក្ដីសម្រេចជាឯកច្ឆន្ទ របស់ អ.ប.ជ គឺធ្វើឱ្យដីកាដំណោះស្រាយត្រូវចាត់ទុកជាមោឃៈ និង គ្មានសុពលភាព នោះឡើយ ដោយហេតុថាសេចក្ដីសម្រេចជាឯកច្ឆន្ទ របស់ អ.ប.ជ នោះឯងគឺជា*ការយល់ឃើញថាគ្មានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពដើម្បីបញ្ជូនសំណុំរឿងទៅជំនុំជម្រះនោះទេ*។[56] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២ បានបង្ហាញអំពីជំហារនេះ ដោយរកឃើញថា "កិច្ចដែលគ្មានសុពលភាព មិនអាចបង្កើតផលវិបាក ឬ លទ្ធផលត្រឹមត្រូវតាមច្បាប់ទេ។ អាស្រ័យហេតុនេះ ជាការសមហេតុផលដែលថា ចំណាត់ការប្រភពដើម ដែលជាដីកាដំណោះស្រាយនីមួយៗនោះ ពុំមានអានុភាពផ្លូវច្បាប់ទេ។"[57]

35. អ.ប.ជ បានរកឃើញថា ការចេញដីកាដំណោះស្រាយចំនួនពីររបស់ ស.ច.ស នៅក្នុងសំណុំរឿង ០០៤ គឺខុសច្បាប់ ហើយ វិធាន១(២) មិនបានផ្ដល់នូវមូលដ្ឋានច្បាប់ដើម្បីបង្វែរពីតម្រូវការនៅក្នុងវិធាន ៦៧(១) ដើម្បីចេញដីកាដំណោះស្រាយតែមួយនោះទេ[58]។ អ.ប.ជ ពិចារណាថា ការចេញដីកាដំណោះស្រាយចំនួនពីររបស់ ស.ច.ស មិនត្រឹមតែចាត់ទុកថាជាកំហុសនីតិវិធីប៉ុណ្ណោះនោះទេ

---

[55] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣៦-៥៧ ជាពិសេស កថាខណ្ឌ ៤៥។

[56] *សំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតធ្វើអន្តរាគមន៍ ក្នុងសំណុំរឿង ០០៤/០២ ស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល* ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០ ឯកសារលេខ E004/2/3 កថាខណ្ឌ ១៥-១៩។ សូមមើលផងដែរ *សំណើរបស់ យឹម ទិត្យ សុំសហចៅក្រមស៊ើបអង្កេតឱ្យ បញ្ចប់ បោះត្រា ដាក់បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារជាបន្ទាន់* ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ឯកសារលេខ D386 កថាខណ្ឌ ១៤-១៧។

[57] សេចក្ដីសម្រេចលើសំណុំរឿង ០០៤/២ កថាខណ្ឌ ៦៧។

[58] សេចក្ដីពិចារណាលើសំណុំរឿង ០០៤ កថាខណ្ឌ ១១០។

ប៉ុន្តែ "វាហួសពីការរំលោភបំពានទៅលើគោលការណ៍ជាមូលដ្ឋាននៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក"[59]។

36. "ការចេញដោយខុសច្បាប់"នៅក្នុងសេចក្តីសម្រេចរបស់ អ.ប.ជ គឺមានន័យដូចនឹង"ទុកជាមោឃៈ និងគ្មានសុពលភាព"។ មេធាវីការពារក្តីបានលើកឡើងនូវអំណះអំណាងនេះនៅចំពោះមុខ អ.ប.ជ និង អ.ជ.ត.ក។[60] តាមការពិត ចៅក្រម អ.ជ.ត.ក ទាំងអស់បានទទួលស្គាល់ចំណុចសំខាន់នៃច្បាប់ ៖ ដីកាបង្គាប់របស់តុលាការដែលគ្មានមូលដ្ឋានច្បាប់ គឺមោឃៈ មានន័យថា ខ្លឹមសារ និងគោលបំណងទាំងអស់ ពុំមានអត្ថិភាពទៀតឡើយ។[61] ស.ព.អ មិនបានផ្តល់ សំអាងហេតុត្រឹមត្រូវសមហេតុផល សម្រាប់ អ.ជ.ត.ក ដើម្បីងាកចេញពីការរកឃើញនេះទេ ដោយគ្រាន់តែអះអាងថា វិធាន ៦៧(១) ត្រូវតែអានក្នុងបរិបទ ហើយភ្ជាប់ជាមួយវិធាន ១(២) "នេះមានន័យថា ស.ច.ស នីមួយៗអាចចេញដីកាដំណោះស្រាយបាន។"[62] អ.ជ.ត.ក បានពិចារណាវិធាន ១(២) នៅក្នុងសំណុំរឿង ០០៤/២ ដោយបានរកឃើញថា "ថាតើវិធាន ១(២) អនុញ្ញាតឱ្យចៅក្រមស៊ើបសួរធ្វើសកម្មភាពរៀងៗខ្លួន ដែលត្រូវតែដោះស្រាយដោយអង្គបុរេជំនុំជម្រះ។"[63] នៅក្នុងការពិចារណាជាបន្តបន្ទាប់នៅក្នុងសំណុំរឿង ០០៣ និង ០០៤ អ.ប.ជ បានបញ្ជាក់ថា វិធាន ១(២) មិន

---

[59] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ២២-២៣, ៤៥-៤៩។ សូមមើល សេចក្តីពិចារណាលើសំណុំរឿង ០០៤ កថាខណ្ឌ ១១៤។

[60] *ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ* ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារលេខD381/26 កថាខណ្ឌ១២-២៦។ *សំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតធ្វើអន្តរាគមន៍ ក្នុងសំណុំរឿង ០០៤/០២ ស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល* ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០ ឯកសារលេខ E004/2/3 កថាខណ្ឌ ១៥-១៩។

[61] សេចក្តីសម្រេចលើសំណុំរឿង ០០៤/២ កថាខណ្ឌ ៥៤ និង ៦៧។

[62] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៤១ ការអះអាងឡើងវិញនូវអំណះអំណាងដែលបានធ្វើឡើងនៅក្នុង *បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ* (D381) ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារលេខ D381/19 កថាខណ្ឌ ១៧៣។

[63] សេចក្តីសម្រេចលើសំណុំរឿង ០០៤/២ កថាខណ្ឌ ៦៨។

អនុញ្ញាតឱ្យចៅក្រមស៊ើបសួរធ្វើសកម្មភាពឯកបុគ្គល និងចេញដីកាដំណោះស្រាយចំនួនពីរ ឡើយ។[64]

37. អ.ជ.ត.ក បានសម្រេចរួចហើយថា គោលជំហរស្វ័យប្រវត្តិមិនអាចអនុវត្តបាន ដោយគ្មានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពឡើយ។[65] ជាងនេះទៅទៀត អ.ជ.ត.ក បានរកឃើញថាអំណះអំណាងដែលបានស្នើដោយ ស.ព.អ ថា"គោលជំហរស្វ័យប្រវត្តិ"ត្រូវអនុវត្តដើម្បីដំណើរការសំណុំរឿង ក្នុងករណីដែលមិនមានសំឡេងគាំទ្រច្រើនលើសលុបសម្រាប់ការលើកលែងការចោទប្រកាន់ "គេចវេស ឬ មិនអើពើអំពីផលវិបាកនៃការយល់ឃើញ*ជាឯកច្ឆន្ទ* របស់អង្គបុរេជំនុំជម្រះ ដែលថាដីកាដំណោះស្រាយ គឺជាលទ្ធផលនៃ*ចំណាត់ការខុសច្បាប់ និងមិនត្រឹមត្រូវតាមច្បាប់*។"[66] ផ្អែកលើការយល់ឃើញជាឯកច្ឆន្ទរបស់ អ.ប.ជ នៅក្នុងសំណុំរឿង ០០៤ និងការសម្រេចជាឯកច្ឆន្ទរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២ មិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពនៅក្នុងសំណុំរឿង ០០៤ នោះទេ។ ស.ព.អ មិនបានផ្តល់ សំអាងហេតុត្រឹមត្រូវសមហេតុផល សម្រាប់ អ.ជ.ត.ក ដើម្បីងាកចេញពីសេចក្តីសម្រេចនេះទេ ហើយពេលនេះពិចារណា ថាសំណុំរឿងអាចបញ្ជូនទៅជំនុំជម្រះ តាមរយៈបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ(ទុកជាមោឃៈ និងគ្មានសុពលភាព) ដែលចេញដោយខុសច្បាប់ ។

38. អ.ជ.ត.ក ក៏បានសម្រេចថាដំណោះស្រាយសមស្របនៅក្នុងករណីបែបនេះ គឺត្រូវតែបញ្ចប់សំណុំរឿង។ អ.ជ.ត.ក បានពិចារណាឃើញថា "ពុំមានការឯកភាពបន្ទាប់ពីរយៈពេលដប់បីឆ្នាំនៃកិច្ចស៊ើបសួរដែល អោ អាន ស្ថិតក្នុងយុត្តាធិការរបស់តុលាការ។ អង្គជំនុំជម្រះពិចារណាឃើញថា ក្នុងករណីពុំមានដីកាដែលអាចអនុវត្តមាន និងជាក់លាក់ ប្រឆាំងនឹង អោ អាន សំណុំរឿង ០០៤/២ ប្រឆាំងនឹងរូបគាត់ គប្បីត្រូវបញ្ចប់នៅចំពោះមុខ អ.វ.ត.ក។"[67] ស.ព.អ មិនបានផ្តល់ សំអាងហេតុត្រឹមត្រូវសមហេតុផល សម្រាប់ អ.ជ.ត.ក ដើម្បីងាកចេញពីសេចក្តីសម្រេចនេះទេ ហើយទៅធ្វើការពិចារណានៅក្នុងសំណុំរឿង ០០៤ ថាតើ ដីកាដំណោះស្រាយទាំងពីរ "បាននាំឱ្យ

---

[64] សំណុំរឿង ០០៣ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ ឯកសារលេខ D266/27 និង D267/35 កថាខណ្ឌ ១០៣ និង ១០៤។ សេចក្តីពិចារណាលើសំណុំរឿង ០០៤ កថាខណ្ឌ ១០៩ និង ១១០។

[65] សេចក្តីសម្រេចលើសំណុំរឿង ០០៤/២ កថាខណ្ឌ ៦៧។

[66] សេចក្តីសម្រេចលើសំណុំរឿង ០០៤/២ កថាខណ្ឌ ៦៧ (សង្កត់ន័យបន្ថែមនៅក្នុងឯកសារដើម)។

[67] សេចក្តីសម្រេចលើសំណុំរឿង ០០៤/២ កថាខណ្ឌ ៦៩។

មានភាពអយុត្តិធម៌ឬទេ" ឬ "បានបណ្ដាលឱ្យមានលទ្ធផលអយុត្តិធម៌ធ្ងន់ធ្ងរទាំងស្រុងនៅក្នុងកិច្ចដំណើរការនីតិវិធីដែរឬទេ" ហើយភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ តម្លៃសង្គមនៃការរារាំងរឿងក្ដីមិនឱ្យបន្តទៅមុខ ផលប្រយោជន៍ និងសិទ្ធិរបស់ភាគីទាំងអស់ និងភាពសមាមាត្រនៃដំណោះស្រាយណាមួយចំពោះព្យសនកម្មដែលបានចោទប្រកាន់"។[68]

39. ស.ព.អ ដាក់សំណើនេះដោយការបង្ហាញការណ៍មិនពិត ឬបំភាន់ ជាមួយនឹងយុត្តិសាស្ត្រមិនសមហេតុផល។ ទីមួយ ស.ព.អ សំអាងខុស លើបទដ្ឋាននៃការត្រួតពិនិត្យលើកំហុសនីតិវិធីដែលអាចដោះស្រាយបាននៅក្នុងសាលក្រម[69] មិនអើពើនឹងសេចក្ដីសម្រេចជាឯកច្ឆ័ន្ទរបស់ អ.ប.ជ ដែលថា ស.ច.ស បានប្រព្រឹត្ត"កំហុសអង្គច្បាប់ធ្ងន់ធ្ងរ"ក្នុងការចេញដីកាដំណោះស្រាយចំនួនពីរធ្វើឱ្យ "ប៉ះពាល់" និង "ធ្វើឱ្យអន្តរាយ" ដល់ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ទាំងមូល។[70] ស.ព.អ ពឹងផ្អែកបន្ថែមទៀតលើសំណុំរឿងក្ដីមិនត្រឹមត្រូវពី តុលាការសិទ្ធិមនុស្សអឺរ៉ុប(ECtHR) លើការកំណត់ "ភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី" និងយុត្តិសាស្ត្រក្នុងច្បាប់ខំមិនឡ (Common Law) ពីសហរដ្ឋអាមេរិក ស្ដីពីការបំបិទចោលភស្តុតាង ដោយបង្ហាញការណ៍មិនពិតពីសំណុំរឿងក្ដីទាំងនោះជា "យុត្តិសាស្ត្រ" ដែលអាចអនុវត្តបាននៅ អ.វ.ត.ក ក្នុងការកំណត់ដំណោះស្រាយសមស្របសម្រាប់ការចេញដីកាដំណោះស្រាយដោយខុសច្បាប់។[71] ជាចុងក្រោយ ស.ព.អ បានលើកយករឿងក្ដីយុត្តិសាស្ត្រដោយបំភាន់ថា សំណុំរឿងអាចត្រូវបានបញ្ចប់ នៅពេលមានការរំលោភបំពានលើកិច្ចដំណើរការ នៅក្នុងករណីពិសេសនៃ "*ការរំលោភបំពានធ្ងន់ធ្ងរ*។"[72]

---

[68] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៤៦។

[69] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ២២ ដោយលើកឡើងអំពីបទដ្ឋាននៃការពិនិត្យបណ្ដឹងឧទ្ធរណ៍របស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០២/០១, *សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារលេខ F36 កថាខណ្ឌ ១០០។

[70] សេចក្ដីពិចារណាលើសំណុំរឿង ០០៤ កថាខណ្ឌ ១១១, ១១២ និង ១១៤។

[71] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ២៣ ជើងទំព័រ ៤៤ ដោយដកស្រង់ *inter alia Ibrahim and others ទល់នឹង ចក្រភពអង់គ្លេស* នៅក្នុងការអនុវត្តរបស់ ECtHR ឯកសារ ៥០៥៤១/០៨, ៥០៥៧១/០៨, ៥០៥៣៧៣/០៨, ០៤៣៥១/០៩, សាលក្រម, ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ កថាខណ្ឌ ២៥២ និង *Hudson ទល់នឹង Michigan* ឯកសារ ៥៤៧ U.S. ៥៨៦, ៥៩១ (២០០៦)។

[72] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥០ ជើងទំព័រ ៩២ ដោយដកស្រង់ សំណុំរឿង ០០២ *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើសុំផ្អាកកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី* (D264/1) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ឯកសារលេខ D264/2/6 កថាខណ្ឌ ២៨។

ផ្ទុយពី ស.ព.អ ការខ្វះការសម្រេចចុងក្រោយចំពោះការស៊ើបអង្កេតអស់រយៈពេល ១៥ ឆ្នាំលើសំណុំរឿងរបស់លោក យឹម ទិត្យ ដែលមិនមានការព្រមព្រៀងគ្នាក្នុងចំណោម សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬ ចៅក្រមនៃ អង្គបុរេជំនុំជម្រះ ថាតើគាត់ស្ថិតក្នុងយុត្តាធិការផ្នែកបុគ្គលរបស់ អ.វ.ត.ក ឬទេនោះ បានបង្កើត "ផលវិបាកធ្ងន់ធ្ងរ" ដល់សិទ្ធិក្នុងការទទួលការជំនុំជម្រះដោយយុត្តិធម៌ ធ្វើឱ្យការបញ្ចប់រឿងក្តីគឺជាដំណោះស្រាយដែលសមស្រប។[73]

40. ស.ព.អ មិនបានផ្តល់ សំអាងហេតុត្រឹមត្រូវសមហេតុផល សម្រាប់ អ.ជ.ត.ក ដើម្បីងាកចេញពីអង្គច្បាប់របស់ខ្លួននៅក្នុងសំណុំរឿង ០០៤/២ នេះមានន័យថាពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងសំណុំរឿង ០០៤ នោះទេ។[74] ដូច្នេះ មូលដ្ឋាន ក, ខ និង គ ត្រូវតែបដិសេធចោល។

**iii.មូលដ្ឋាន ឃ៖ ស.ព.អ បានដាក់បណ្តឹងសាទុក្ខដោយមិនត្រឹមត្រូវ ចំពោះមតិដាច់ដោយឡែករបស់ អ.ប.ជ ដែលមាន*"ភាពមិនពាក់ពន្ធ័"***

41. នៅក្នុងមូលដ្ឋាន ឃ, ស.ព.អ បានដាក់បណ្តឹងសាទុក្ខលើផ្នែកមតិយោបល់ដាច់ដោយឡែករបស់សហចៅក្រមជាតិនៃ អ.ប.ជ ដោយអះអាងថា សំណុំរឿង ០០៤ គឺមិនខុសច្បាប់។[75]

42. អ.ជ.ត.ក បានសម្រេចរួចហើយថាការប្រកាសចេញដីកាដំណោះស្រាយចំនួនពីរជាលទ្ធផលនៃ *"ចំណាត់ការខុសច្បាប់ និងមិនត្រឹមត្រូវតាមច្បាប់"* ហើយ ផ្នែកមតិយោបល់ដាច់ដោយឡែករបស់ចៅក្រមនៃ អ.ប.ជ គឺ "មិនពាក់ព័ន្ធ" "ជាការអនុវត្តមិនចាំបាច់" និង "ច្រំដែល"[76]។ ស.ព.អ មិនបានផ្តល់ សំអាងហេតុត្រឹមត្រូវសមហេតុផលសម្រាប់ អ.ជ.ត.ក ដើម្បីងាកចេញពី អង្គច្បាប់របស់ខ្លួនឡើយ។ ដូច្នេះ មូលដ្ឋាន ឃ ត្រូវតែបដិសេធចោលដោយសារមិនមានភាពពាក់ព័ន្ធ។[77]

---

[73] សំណុំរឿង ០០៣ *សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង* ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ឯកសារលេខ D270/7 កថាខណ្ឌ ២៥-២៧។ សូមមើលផងដែរ សេចក្តីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៦៩។

[74] ដូចមានខាងលើ កថាខណ្ឌ ១៨-១៩។

[75] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥៨-៧១។

[76] សេចក្តីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៥៣, ៦៧ (សង្កត់ន័យបន្ថែមនៅក្នុងឯកសារដើម)។

[77] ដូចមានខាងលើ កថាខណ្ឌ ១៨-១៩។

**អាស្រ័យហេតុនេះ** យោងតាមសំអាងហេតុទាំងអស់ដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមស្នើដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូល មេត្តា៖

(1) **បដិសេធ** មិនអនុវត្តយុត្តាធិការដែលមានជាប់មកជាមួយរបស់ខ្លួនលើសំណុំរឿង ០០៤ ដោយសារតែនៅពេលនេះ ស.ច.ស មានយុត្តាធិការផ្តាច់មុខ។

(2) **បដិសេធ** បណ្តឹងសាទុក្ខរបស់ ស.ព.អ តាំងពីដំបូង (*in limine*)។

*ឬម៉្យាងវិញទៀត*

(3) **សម្រេចថា** មូលដ្ឋាន ក, ខ និង គ មិនអាចទទួលយកបាន ដោយសារវាស្វែងរកការដោះស្រាយឡើងវិញដោយមិនត្រឹមត្រូវនូវបញ្ហាដែលត្រូវបានសម្រេចរួចមកហើយ មកធ្វើជាចំណុចវិវាទសារជាថ្មី និងមិនអាចទទួលយកបាន ដោយអនុលោមតាមវិធាន ១០៤(១) និង ១០៥(៤)។

(4) **សម្រេចថា** មូលដ្ឋាន ឃ មិនមានភាពពាក់ព័ន្ធ និង មិនអាចទទួលយកបាន ដោយអនុលោមតាមវិធាន ១០៤(១) និង ១០៥(៤)។

(5) **បដិសេធ** បណ្តឹងសាទុក្ខរបស់ ស.ព.អ តាំងពីដំបូង (*in limine*)។

សូមអង្គជំនុំជម្រះតុលាការកំពូលមេត្តាទទួលយកចម្លើយតបនេះដោយគោរព។

| | |
|---|---|
| **សូ មូស្សេទ្ទី** | **Suzana TOMANOVIĆ** |

សហមេធាវីការពារក្តីលោក យឹម ទិត្យ

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០២១